ជំពូកទី ៨

# របៀបកំណត់កម្រិតថ្នាំ និងរបៀបប្រើថ្នាំ

**និមិត្តសញ្ញា**

= មានន័យថា ៖ ស្មើនឹង ឬដូចគ្នានឹង

+ មានន័យថា ៖ និង ឬបូកនឹង



1 + 1 = 2

មួយ បូក មួយ ស្មើនឹង ពីរ

**របៀបសរសេរក្នុងការចែកថ្នាំ**

១គ្រាប់ = មួយគ្រាប់ទាំងមូល = 

១/២គ្រាប់ = កន្លះគ្រាប់ = 

១ ១/២គ្រាប់ = មួយគ្រាប់កន្លះ = 

១/៤គ្រាប់ = មួយភាគបួននៃគ្រាប់ = 

១/៨គ្រាប់ = មួយភាគប្រាំបីនៃគ្រាប់(មួយគ្រាប់ចែកជាប្រាំបីចំណែក ហើយលេបមួយចំណែក) = 

## ខ្នាតរង្វាស់របស់ថ្នាំ

ជាទូទៅ ខ្នាតរង្វាស់របស់ថ្នាំគឺគិតជាក្រាម(ក្រ.)និងមីលីក្រាម(ម.ក្រ)

១០០០ម.ក្រ.= ១ក្រ. (មួយពាន់មីលីក្រាម ស្មើនឹងមួយក្រាម)

១ម.ក្រ=0,00១ក្រ. (មួយមីលីក្រាមស្មើនឹងមួយភាគពាន់នៃមួយក្រាម)

**ឧទាហរណ៍**

| | | | |
|---|---|---|---|
|  | អាស្ពីរីន(Aspirin)សម្រាប់មនុស្សធំមួយគ្រាប់ មានផ្ទុកថ្នាំអាស្ពីរីន ៣០០មីលីក្រាម | .៣ ក្រ.<br>០.៣ ក្រ.<br>០.៣០០ ក្រ.<br>៣០០ ម.ក្រ. | ទាំងអស់នេះជារបៀបផ្សេងៗគ្នានៃការនិយាយអំពី ៣០០មីលីក្រាម |
|  | អាស្ពីរីន(Aspirin) សម្រាប់កុមារមួយគ្រាប់ មានផ្ទុកថ្នាំអាស្ពីរីន ៧៥មីលីក្រាម | .០៧៥ ក្រ.<br>០.០៧៥ ក្រ.<br>៧៥ ម.ក្រ. | ទាំងអស់នេះជារបៀបផ្សេងៗគ្នានៃការនិយាយអំពី ៧៥មីលីក្រាម |

*កំណត់ចំណាំ ៖* នៅក្នុងប្រទេសខ្លះ ថ្នាំខ្លះមានខ្នាតរង្វាស់គិតជា ហ្គ្រេន (grain=gr.) ហើយ ១gr. = ៦៥ ម.ក្រ.។ នេះមានន័យថា ថ្នាំអាស្ពីរីនមួយគ្រាប់ដែលមាន ៥gr. គឺស្មើនឹង ៣០០ ម.ក្រ.។

ជាទូទៅ គេចាំបាច់ត្រូវដឹងពីចំនួនក្រាម ឬមីលីក្រាមដែលមានផ្ទុកនៅក្នុងថ្នាំណាមួយ។

ឧទាហរណ៍ ៖ បើអ្នកចង់ប្រើថ្នាំគ្រាប់អាស្ពីរីនសម្រាប់មនុស្សធំមួយចំណែកតូច ឲ្យទៅកុមារជំនួសថ្នាំអាស្ពីរីនសម្រាប់កុមារ ប៉ុន្តែអ្នកមិនដឹងថាត្រូវឲ្យប៉ុន្មាននោះ...

អានអក្សរតូចៗនៅលើស្លាកសញ្ញារបស់ថ្នាំ
ដែលមានសរសេរថា ៖ អាស៊ីត
អាសេទីលសាលីស៊ីលិក ០.៣ក្រាម
(អាសេទីលសេលីស៊ីលិក អាស៊ីដ = អាស្ពីរីន)




០.៣ ក្រ. = ៣០០ ម.ក្រ. និង ០.០៧៥ ក្រ. = ៧៥ ម.ក្រ.។ ដូច្នេះអ្នកអាចមើលឃើញថា ថ្នាំអាស្ពីរីនសម្រាប់មនុស្សធំ ១គ្រាប់ មានទម្ងន់ស្មើនឹង៤ដងនៃអាស្ពីរីនសម្រាប់កុមារ។




បើអ្នកកាត់អាស្ពីរីនមនុស្សធំ ១គ្រាប់ទៅជា៤ភាគស្មើៗគ្នា នោះមួយភាគៗនៃអាស្ពីរីនទាំង ៤ភាគ ស្មើនឹងអាស្ពីរីនសម្រាប់កុមារមួយគ្រាប់






ដូច្នេះ បើអ្នកកាត់អាស្ពីរីនមនុស្សធំ១គ្រាប់ទៅជា៤ចំណែក អ្នកអាចប្រើ១ចំណែកជំនួសអាស្ពីរីនសម្រាប់កុមារបាន។ របៀបទាំងពីរយ៉ាងនេះស្មើគ្នា ប៉ុន្តែមួយចំណែកនៃអាស្ពីរីនមនុស្សធំមានតម្លៃថោកជាង។

ប្រយ័ត្ន ៖ មានថ្នាំជាច្រើន ពិសេសពពួកថ្នាំអង់ទីប៊ីយ៉ូទិកមានទម្ងន់ និងខ្នាតខុសគ្នា។

ឧទាហរណ៍ ៖ តេត្រាស៊ីគ្លីន (Tetracycline) អាចមានគ្រាប់៣ប្រភេទ ៖




**សូមប្រយ័ត្នថា ត្រូវឲ្យថ្នាំតែទៅតាមកម្រិតដែលបានណែនាំប៉ុណ្ណោះ។** គេចាំបាច់ត្រូវពិនិត្យថា តើថ្នាំនោះមានចំណុះប៉ុន្មានក្រាម ឬមីលីក្រាម។

ឧទាហរណ៍ ៖ បើនៅក្នុងវេជ្ជបញ្ជាសរសេរថា លេបតេត្រាស៊ីគ្លីន ១គ្រាប់ ២៥០ម.ក្រ. ចំនួន៤ដង ក្នុងមួយថ្ងៃ ហើយអ្នកមានតែគ្រាប់៥០ម.ក្រ នោះអ្នកត្រូវលេប៥គ្រាប់នៃ៥០មីលីក្រាម ៤ដងក្នុងមួយថ្ងៃ (២០គ្រាប់ ក្នុងមួយថ្ងៃ)។




## របៀបកំណត់កម្រិតថ្នាំប៉េនីស៊ីលីន

ជាទូទៅ ថ្នាំប៉េនីស៊ីលីនត្រូវបានកម្រិតជាអ៊ុយនីតេ (unit) ១.៦០០.០០០អ៊ុយនីតេ = ១ក្រ. ឬ ១.០០០ម.ក្រ ថ្នាំប៉េនីស៊ីលីនមានច្រើនទម្រង់ (ថ្នាំចាក់និងថ្នាំគ្រាប់) ក្នុងកម្រិត ៤០០.០០០អ៊ុយនីតេ = ២៥០ម.ក្រ.

## ខ្នាតរង្វាស់ថ្នាំទឹក

ថ្នាំស៊ីរ៉ូ ថ្នាំទឹកខាប់ៗ ថ្នាំកម្លាំង និងថ្នាំទឹកផ្សេងៗទៀតត្រូវបានកំណត់ក្រិតជាមីលីលីត្រ ៖

ម.ល = មីលីលីត្រ　　　　　　　　　　១លីត្រ(ល.) = ១០០០ម.ល

ជាញឹកញាប់ ថ្នាំទឹកត្រូវបានគេវាល់ដោយស្លាបព្រាបាយ ឬស្លាបព្រាកាហ្វេ ៖

១ស្លាបព្រាកាហ្វេ = ៥.ម.ល　　　　　　　　　　១ស្លាបពាប្រាយ = ១៥ម.ល



កាលណាគេណែនាំថា ពិសារមួយស្លាបព្រាកាហ្វេ បានសេចក្តីថា ៥ម.ល។

ប៉ុន្តែ ស្លាបព្រាកាហ្វេដែលគេច្រើនប្រើមានកម្រិតដល់៨ម.ល ឬត្រឹម៣ម.ល។ **បើប្រើស្លាបពាក្រាហ្វេដើម្បីឲ្យថ្នាំ នោះ គេចាំបាច់ត្រូវវាស់ត្រឹមតែ៥ម.ល ដោយមិនឲ្យលើស និងមិនឲ្យខ្វះឡើយ។**

## វិធីធ្វើឲ្យប្រាកដថាស្លាបព្រាកាហ្វេដែលប្រើមានចំណុះ៥ម.ល

១. ទិញស្លាបព្រាដែលមានចំណុះ៥ម.ល



ឬ




២. ទិញថ្នាំដែលមានស្លាបព្រាប្លាស្ទិកជាប់មកជាមួយ។ ស្លាបព្រានេះមានចំណុះ ៥ម.ល។ នៅពេលដែលវាពេញ វាមានចំណុះ ៥ម.ល ហើយបើវាកន្លះ វាមានគំនូសបង្ហាញមួយ (២.៥ម.ល)។ រក្សាទុកស្លាបព្រានេះសម្រាប់ក្រិតថ្នាំផ្សេងៗទៀត។

ឬ

៣. ចាក់បំពេញស្លាបព្រាតូចណាមួយដែលមាននៅផ្ទះរបស់អ្នក ក្នុងចំណុះទឹក៥ម.ល ដោយប្រើស៊ីរ៉ាំង ឬវត្ថុផ្សេងទៀតសម្រាប់វាស់ **ហើយគូសចំណាំនៅលើស្លាបព្រានោះ នៅត្រង់កម្រិតកម្ពស់ទឹកនោះ។**



# របៀបឲ្យថ្នាំដល់កុមារតូចៗ

មានថ្នាំជាច្រើនប្រភេទដែលមានទម្រង់ជាគ្រាប់ ក៏មានទម្រង់ជាស៊ីរ៉ូ ឬទឹកខាប់ៗផងដែរ សម្រាប់កុមារ។ ជាទូទៅ បើអ្នកប្រៀបធៀបចំណុះថ្នាំដែលអ្នកទិញ ថ្នាំស៊ីរ៉ូតែងតែថ្លៃជាងថ្នាំគ្រាប់។ អ្នកអាចសំចៃលុយដោយធ្វើស៊ីរ៉ូដោយខ្លួនអ្នកតាមរបៀបដូចខាងក្រោម ៖




នៅពេលអ្នកធ្វើស៊ីរ៉ូសម្រាប់កុមារពីថ្នាំគ្រាប់ **ត្រូវប្រយ័ត្ន កុំឲ្យថ្នាំច្រើនហួសពេក។** និង**មិនត្រូវឲ្យទឹកឃ្មុំទៅកុមារដែលមានអាយុក្រោមមួយឆ្នាំ។** ទោះបីជាវាជាករណីក៏ដោយ ក៏ទារកខ្លះអាចមានប្រតិកម្មដ៏គ្រោះថ្នាក់ដែរ។

*ប្រយ័ត្ន ៖* ដើម្បីបង្ការការឈ្លក់ មិនត្រូវឲ្យថ្នាំទៅកុមារនៅពេលដែលវាដេកផ្ងារ ឬនៅពេលក្បាលរបស់វាត្រូវបានសង្កត់ទៅក្រោយ។ ត្រូវប្រាកដថា កុមារនោះអង្គុយ ឬក្បាលរបស់កុមារនោះត្រូវបានងើបឡើងលើ។ មិនត្រូវឲ្យថ្នាំពេទ្យទៅកុមារតាមមាត់ នៅពេលដែលវាកំពុងប្រកាច់ ឬពេលវាដេកលក់ ឬពេលវាសន្លប់បាត់ស្មារតីនោះឡើយ។

### តើត្រូវឲ្យថ្នាំប៉ុន្មានដល់កុមារ នៅពេលដែលអ្នកមានតែថ្នាំសម្រាប់មនុស្សធំ?

ជាទូទៅកាលណាកុមារកាន់តែតូច នោះថ្នាំដែលត្រូវឲ្យកាន់តែតិច។ ការឲ្យថ្នាំហួសកម្រិតអាចបណ្ដាលឲ្យមានគ្រោះថ្នាក់។ បើអ្នកមានព័ត៌មានអំពីកម្រិតថ្នាំសម្រាប់កុមារ សូមធ្វើតាមការណែនាំនោះដោយប្រុងប្រយ័ត្ន។ បើអ្នកមិនដឹងពីកម្រិតប្រើប្រាស់ គិតទៅតាមទម្ងន់ ឬអាយុរបស់កុមារនោះ។ តាមធម្មតា គេគួរឲ្យថ្នាំកុមារតាមចំណែកនៃកម្រិតមនុស្សធំដូចខាងក្រោមនេះ ៖



# របៀបលេបថ្នាំ




វាជាការសំខាន់ណាស់ដែលគេត្រូវលេបថ្នាំតាមការណែនាំ។ ថ្នាំខ្លះត្រូវលេបតែម្តង ក្នុងមួយថ្ងៃ ប៉ុន្តែថ្នាំខ្លះទៀតត្រូវលេបឲ្យបានច្រើន។ ប្រសិនបើអ្នកគ្មាននាឡិកា ក៏គ្មានបញ្ហាអ្វីដែរ ។ ប្រសិនបើការណែនាំប្រាប់ថា( ១គ្រាប់ រៀងរាល់៨ម៉ោងម្តង ) មានន័យថា លេប៣ដងក្នុង១ថ្ងៃ ១គ្រាប់ពេលព្រឹក ១គ្រាប់ ពេលរសៀល និង១គ្រាប់ពេលយប់។ ប្រសិនបើគេនិយាយថា( ១គ្រាប់រៀងរាល់ ៦ម៉ោងម្តង ) មានន័យថា លេប៤ដងក្នុងមួយថ្ងៃ ១គ្រាប់នៅពេលព្រឹក ១គ្រាប់នៅពេលថ្ងៃត្រង់ ១គ្រាប់នៅពេលរសៀល និង១គ្រាប់នៅយប់។ ប្រសិនបើការណែនាំប្រាប់ថា( ១គ្រាប់រៀងរាល់ ៤ម៉ោងម្តង ) មានន័យថាលេប៦ដងក្នុង១ថ្ងៃ ដោយមានចន្លោះពេលនៃការលេបម្តងៗ ប្រហែលគ្នា។

នៅរាល់ពេលដែលអ្នកឲ្យថ្នាំពេទ្យទៅនរណាម្នាក់ ជាការល្អអ្នកត្រូវសរសេរសេចក្តីណែនាំ និងឲ្យអ្នកជំងឺប្រាប់អ្នកឡើងវិញពីរបៀបប្រើថ្នាំ និងពេលដែលត្រូវលេបថ្នាំ។ ត្រូវធ្វើឲ្យប្រាកដថាគាត់យល់ច្បាស់។

*ដើម្បីរំលឹកដល់អ្នកមិនចេះអាន អំពីពេលដែលត្រូវលេបថ្នាំ អ្នកអាចធ្វើសញ្ញាសំគាល់ដូចនេះ*

*នៅកន្លែងទំនេរខាងក្រោមនេះ គូរចំនួនថ្នាំដែលត្រូវលេប និងពន្យល់គេឲ្យបានច្បាស់លាស់ តើវាមានន័យដូចម្តេច។*



*ឧទាហរណ៍ ៖*

*នេះមានន័យថា ១គ្រាប់ បួនដងក្នុងមួយថ្ងៃ ១គ្រាប់ពេលព្រឹក ១គ្រាប់ពេលរសៀល ១គ្រាប់ពេលល្ងាច និង ១គ្រាប់ពេលយប់*



*នេះមានន័យថា កន្លះគ្រាប់ លេប៤ដងក្នុង១ថ្ងៃ*



*នេះមានន័យថា ១គ្រាប់ លេប៣ដងក្នុង១ថ្ងៃ*



*នេះមានន័យថា ១ភាគ៤នៃគ្រាប់ លេប២ដងក្នុង១ថ្ងៃ*



*នេះមានន័យថា ២ស្លាបព្រាកាហ្វេ ២ដងក្នុង១ថ្ងៃ*



### ពេលដែលអ្នកឲ្យថ្នាំដល់នរណាម្នាក់...

ត្រូវសរសេរព័ត៌មានដូចខាងក្រោមនេះនៅលើកំណត់សំគាល់ដែលភ្ជាប់ជាមួយនឹងថ្នាំជានិច្ច ទោះអ្នកនោះមិនចេះអានអក្សរក៏ដោយ ៖

- ឈ្មោះអ្នកជំងឺ
- ឈ្មោះថ្នាំ
- សម្រាប់ជំងឺអ្វី
- កម្រិតប្រើ



*ព័ត៌មានទាំងនេះ ក៏អាចសរសេរនៅខាងក្រោមសញ្ញាសំគាល់អំពីរបៀបប្រើថ្នាំដែរ*

ទំព័រទំនេរស្តីអំពីរបៀបប្រើថ្នាំមាននៅផ្នែកខាងក្រោយនៃសៀវភៅនេះ។ អ្នកអាចហែកវាមកប្រើបាន ប្រសិនបើត្រូវការ។ បើប្រើអស់ អ្នកអាចធ្វើវាបន្ថែមទៀតដោយខ្លួនឯង។

នៅពេលដែលអ្នកឲ្យថ្នាំទៅនរណាម្នាក់ ដើម្បីជាការល្អ អ្នកគួររក្សាទុកឲ្យបានត្រឹមត្រូវនូវកំណត់ត្រានៃព័ត៌មានដូចគ្នានេះ។ ប្រសិនបើធ្វើបាន រក្សាទុកនូវកំណត់ហេតុពេញលេញរបស់អ្នកជំងឺ( ទំ.៤៤ )។

### ការលេបថ្នាំពេលក្រពះពេញ ឬក្រពះទទេ

ថ្នាំខ្លះមានប្រសិទ្ធភាពល្អបំផុត កាលណាអ្នកលេបវាពេលក្រពះទទេ គឺលេបមួយម៉ោងមុនពេលបរិភោគអាហារ។

ថ្នាំខ្លះទៀតមិនធ្វើទុក្ខក្រពះ ឬចុកចុងដង្ហើមទេ កាលណាលេបវាក្នុងពេលបាយ ឬក្រោយពេលបាយរួចភ្លាម។

ប្រើថ្នាំទាំងនេះ១ម៉ោងមុនពេលបាយ

- ប៉េនីស៊ីលីន( Penicillin )
- អំពីស៊ីលីន( Ampicillin )
- តេត្រាស៊ីគ្លីន( Tetracycline )

ជាការល្អ កុំផឹកទឹកដោះគោ មួយម៉ោងមុន ឬក្រោយពេលប្រើថ្នាំតេត្រាស៊ីគ្លីន។

លេបថ្នាំទាំងនេះក្នុងពេលបាយ ឬភ្លាមៗក្រោយពេលបាយ( ឬផឹកទឹកឲ្យច្រើន )

- អាស្ពីរីន( Aspirin ) និងថ្នាំដែលមានជាតិអាស្ពីរីន
- ជាតិដែក
- ថ្នាំវីតាមីន
- អេរីត្រូមីស៊ីន( Erythromycin )

ថ្នាំអង់តាស៊ីតមានប្រសិទ្ធិភាពណាស់ បើលេបវានៅពេលពោះទទេ មួយឬពីរម៉ោងក្រោយបាយ និងពេលដេក។

*កំណត់ចំណាំ ៖* វាជាការប្រសើរណាស់ដែលលេបថ្នាំនៅពេលដែលអ្នកឈរ ឬអង្គុយ។ ម៉្យាងទៀត ត្រូវផឹកទឹកឲ្យបានមួយកែវនៅរាល់ពេលលេបថ្នាំ។ ប្រើសិនបើអ្នកលេបថ្នាំសុលហ្វា ដើម្បីជាការល្អ **ត្រូវផឹកទឹកឲ្យច្រើន** យ៉ាងតិចបំផុត ៨កែវក្នុងមួយថ្ងៃ ដើម្បីបង្ការគ្រោះថ្នាក់ដល់តម្រងនោម។